**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៤០ គ.ជ.ប.ស.ណ.ន

# សេចក្ដីណែនាំ
# ស្ដីពី
# ប្រភេទឯកសារដែលអនុញ្ញាតឱ្យប្រើប្រាស់ សម្រាប់ការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨

- យោងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨
- យោងសេចក្ដីណែនាំរួមលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតរបស់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងតាមសំណូមពរចាំបាច់នៃការងារ ។

ក្នុងគោលបំណងធានាដល់សិទ្ធិក្នុងការបោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧ ប៉ុន្តែមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួនបាត់ ឬខូច គ.ជ.ប សូមធ្វើការណែនាំ ដូចខាងក្រោម ៖

ប្រភេទឯកសារ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត រួមមាន ៖
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ទាំងបីប្រភេទរួមមាន ប្រភេទទី១ ឬទី២ ឬទី៣
- ឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការបោះឆ្នោត (ឯ.អ)
- ឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ (ឯ.អ) ដែលមានបញ្ជាក់ពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧ ដោយគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ។

ក្នុងករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧ បានប្រើប្រាស់ អ.ខ ដើម្បីចុះឈ្មោះបោះឆ្នោត ប៉ុន្តែ អ.ខ របស់គាត់បានបាត់ ឬខូច ប្រជាពលរដ្ឋនោះត្រូវស្នើសុំ ឯ.អ បម្រើឱ្យការបោះឆ្នោត ស្របតាមលក្ខខណ្ឌ និងនីតិវិធី ដូចចែងក្នុង និងក្រោមចំណុចធំ III នៃសេចក្តីណែនាំរួមលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និង គ.ជ.ប ។

ក្នុងករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧ បានប្រើប្រាស់ ឯ.អ ដើម្បីចុះឈ្មោះបោះឆ្នោត និងនៅមិនទាន់បានទទួល អ.ខ សម្រាប់បោះឆ្នោត ប្រជាពលរដ្ឋនោះអាច ៖

- ស្នើសុំ ឯ.អ បម្រើឱ្យការបោះឆ្នោត តាមលក្ខខណ្ឌ និងនីតិវិធី ដូចចែងក្នុង និងក្រោមចំណុចធំ III នៃសេចក្តីណែនាំរួមលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និង គ.ជ.ប ។
- យក ឯ.អ បម្រើឱ្យការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ ទៅបញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧ នៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត តាមនីតិវិធីដូចចែងក្នុង និងក្រោមប្រការ ៦.៨ នៃ ប.ន.ត.រ ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោតឆ្នាំ២០១៨ ។

អគ្គលេខាធិការ គ.ជ.ប គធ.ខប និង គឃ.សប ត្រូវចាត់ចែងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ណែនាំ និងអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសុក្រ ៦រោច ខែមេសា ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១៨

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

សិក ប៊ុនហុក